# ការសំភាសន៍របស់ សំ ស៊ីណា

ក៖ អ្នកដែរសំភាសន៍ ជាង ស៊ីអ៊ារ ខ៖ អ្នកដែរអោយគេសំភាសន៍ សំ ស៊ីណា

ក៖ ចឹងជាដំបូងពូដែរបានអោយខ្ញុំបានសំភាសន៍ដែរទាក់ទងពីប្រវត្តិរបស់ពូ ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចហាសពូ ដែរមានឈ្មោះថាBYUហាសពូ ហើយដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាយប្រវត្តិប្រជាជនខ្មែរ ដើម្បីអោយពួកគាត់បានស្គាល់ពីប្រវត្តិឪពុកម្តាយនឹងដូនតាចឹងហាសពូ ចឹងពេលដែរខ្ញុមសំភាសន៍ពូហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាហាសពូដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសពូ ចុះពូយល់ព្រមដើម្បីអើយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេពូ?

ខ៖ ដាក់នៅសាលាណាដែរ?

ក៖ សាលាដែរខ្ញុំដាក់នៅអាមេរិចហាសពូ តើពូយល់ព្រមទេពូ?

ខ៖ ចុះគ្រាន់តែយើងដាក់នៅសាលានឹងមានតែអី

ក៖ អូបាទពូ ចឹងសំរាប់ខ្ញុំជាអ្នកដែរសំភាសន៍ពូខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយការសំភាសន៍នេះត្រូវបានធ្វើនៅថ្ងៃទី27 ខែ1 ឆ្នាំ 2018ហាសពូ ហើយត្រូវបានរៀបចំធ្វើនៅភូមិ4 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញហាសពូ ចឹងសំរាប់ពូមានឈ្មោះអីគេដែរពូឈ្មោះពេញហាស?

ខ៖ ខ្ញុំឈ្មោះសំ ស៊ីណា

ក៖ ឈ្មោះសំ ស៊ីណា ចុះពូមានឈ្មោះហៅក្រៅទេពូ?

ខ៖ មានៗៗតា

ក៖ គេហៅឈ្មោះអីគេដែរពូ?

ខ៖ គេហៅថាចាប់ប្រុស

កៈ អូឈ្មោះ ចាប់ប្រុស?

ខៈ នឹងហើយ

កៈ ចុះកាលពីក្មេងមាននរណាហៅពូអីផ្សេងទៀតទេពូ?

ខៈ កាលនៅពីក្មេងអតមានហៅឈ្មោះផ្សេងទេ

កៈ ចឹងមានឈ្មោះតែចាប់ ប្រុស នឹង សំ ស៊ីណានឹង?

ខៈ នឹងហើយបើនៅក្នុងបញ្ជីជាតិគេហៅ សំ ស៊ីណានឹងឯង

កៈ ចុះពូសព្វថ្ងៃនឹងពូមានអាយុប៉ុន្មានដែរពូ?

ខៈ ខ្ញុំអាយុ43ឆ្នាំ

កៈ ពូអាយុ43ឆ្នាំ ចុះពូមានដឹងថាថ្ងៃខែឆ្នាំពូមានចងចាំទេ?

ខៈ ខ្ញុំអត់ចាំទេ

កៈ ចុះថ្ងៃណាខែណាក៏ពូអត់ចាំដែរ?

ខៈ អត់ទេ

កៈ ចឹងពូកើតនៅឆ្នាំ1975អូចំពលពតតែម្ដងនឹងហោសពូ?

ខៈ នឹងហើយត្រូវហើយ

កៈ ចុះពូកើតនៅឆ្នាំខ្មែរហាស ដូចជាឆ្នាំជូត ឆ្លូវ ខាល ថោះហាសពូឆ្នាំអីគេដែរពូ?

ខៈ ខ្ញុំកើតឆ្នាំជេស

កៈ ចុះឆ្នាំខ្មែរពូកើតឆ្នាំអីគេដែរពូ?

ខៈ ខ្ញុំឆ្នាំជូត

កៈ អូឆ្នាំជូតហោសពូ ចុះពូកើតនៅភូមិអី ឃុំអី ស្រុកអីពូមានចងចាំទេ?

ខៈ ខ្ញុំកើតនៅភូមិសំរោង ឃុំគ្រួស នៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង

កៈ អូបាទពូប៉ុន្តែពូសព្វថ្ងៃនឹងពូមានបងប្អូនប៉ុន្មាននាក់ដែរពូ?

ខ៖ ខ្ញុំបានបងប្អូន6នាក់ ប៉ុន្តែស្លាប់ម្នាក់ហើយនឹង

ក៖ អូស្លាប់ម្នាក់ ចុះពូជាកូនទីប៉ុន្មានដែរពូ?

ខ៖ ខ្ញុំជាកូនទី2

ក៖ ចុះមានស្រីប៉ុន្មាន ហើយប្រុសប៉ុន្មានដែរពូ?

ខ៖ មានស្រី2នាក់ នឹងប្រុស4នាក់

ក៖ អូមានស្រី2នាក់ នឹងប្រុស4នាក់ ចុះអ្នកដែរស្លាប់នឹងកូនទីប៉ុន្មានដែរពូ?

ខ៖ ស្លាប់កូនទី1នឹង

ក៖ អូកូនទី1អូបងគេហោសពូ?

ខ៖ នឹងហើយបងគេ

ក៖ បន្ទាប់មកបានពូ ចឹងមានន័យថាពូក្លាយជាបងគេវិញហើយពូ?

ខ៖ ត្រូវហើយនឹង

ក៖ ចុះប្អូនរបស់ពូគាត់មានឈ្មោះអីគេដែរពូ
រឺបងរបស់ពូគាត់មានឈ្មោះអីគេដែរពូអាចប្រាប់បានទេពូ?

ខ៖ ឈ្មោះ សំ ស៊ីណាត

ក៖ ឈ្មោះ សំ ស៊ីណាត សំរាប់ពូសំ ស៊ីណា ចុះទី3ឈ្មោះអីគេដែរពូ?

ខ៖ ទី3ស្រី ឈ្មោះចិន្តា

ក៖ ឈ្មោះចិន្តាណាពូ?

ខ៖ ឈ្មោះ ចិន្តា , ផល្លា, រចនា

ក៖ ផល្លាទី4 នឹងរចនាទី5 ចុះទី6ឈ្មោះអីគេដែរពូ?

ខ៖ ទី6ប្រុស សំរេច

ក៖ ចឹងមានន័យថាឈ្មោះ ប្រុស សំរេច អូពូនឹង៣គេ?

ខ៖ នឹង៣គេ

ក៖
ចុះពូមានចងចាំអនុស្សាវរីយ៍អីដូចជាពូធ្លាប់ធ្វើអីគេខ្លះជាមួយបងប្អូនរបស់ពូកាលពូនៅពីក្មេងហាសពូ?

ខ៖ ធ្វើស្រែ មើលគោ

ក៖ ចុះឡើងដើមត្នោតពូធ្លាប់ទេ នឹងលេងទឹកលេងអីចឹងហាសពូ?

ខ៖ នឹងលេងទឹកលេងអីចឹងទៅ នៅក្មេងហាស

ក៖ ចុះពូមានធ្លាប់បាញ់ឃ្លី រឺក៏គប់ឈូស អីទេពូ?

ខ៖ មានលេង

ក៖ អូមានលេងណាពូ?

ខ៖ ដូចមានលេងចោលឈូង ទាញព្រាត លាក់កន្សែងដូចក្មេងឥឡូវនឹង

ក៖ ជុះពូធ្លាប់លេងធ្លាប់លេងពង្រត់ដៃកូនក្រមុំទេពូ?

ខ៖ អត់មានទេអត់ដែរទេ

ក៖ អូកាលពីជំនាន់ណុងអត់មានទេណាពូ?

ខ៖ នឹងហើយ

ក៖ អូចុះពូមានធ្លាប់លេងឡឹកបាយឡ រឺមួយក៏លេងបិទពួនអីជាមួយបងប្អូនទេ?

ខ៖ មានលេង

ក៖ អូចឹងកាលណុងពូអាយុប៉ុន្មានហើយពូ?

ខ៖ កាលណុងខ្ញុំអាយុ5-6ឆ្នាំហើយយ៉ាង

ក៖ អូចុះបងរបស់ពូដូចជាគាត់ស្លាប់នៅពេលណាដែរទៅពូ?

ខ៖ គាត់ទើបតែស្លាប់ដែរនឹង

កៈ ចុះគាត់ស្លាប់ប៉ុន្មានឆ្នាំទៅពូ?

ខៈ គាត់ស្លាប់ប្រហែលជា5ឆ្នាំហើយមើលទៅ

កៈ អូប្រហែលជា5-6ឆ្នាំណាពូ អូចុះពូខ្ញុំសុំសួរតិចហេតុអីបានជាគាត់ស្លាប់បានទេពូ ដូចជាគាត់ស្លាប់ដោយសារតែជំងឺមែនពូ?

ខៈ អានឹងដោយសារតែជំងឺគាត់មើលមិនជា

កៈ ចុះគាត់កាលណុងគាត់អាយុប៉ុន្មានដែរហើយពូ?

ខៈ គាត់អាយុប្រហែលជា43-44ឆ្នាំដែរនឹង

កៈ អូចឹងគាត់បងពូ1-2ឆ្នាំណាពូ
ចុះពូគិតថាកាលពីក្មេងហាសពូចូលលេងអីគេជាមួយបងប្អូនរបស់ពូដែរហោសពូ មិញពូលេងជាមួយគាត់ តែនេះពូចូលចិត្តលេងអីជាមួយគាត់ដែរហាស?

ខៈ ចូលចិត្តប្រលែងគ្នា

កៈ ទៅស្រែអីនឹង?

ខៈ នឹងហើយទៅស្រែនឹង ចឹងទៅលេងប្រណាំងគ្នាអីចឹងទៅ

កៈ អូលេងប្រណាំងទូកហោសពូ?

ខៈ ហោសទូកមិនដែរទេ

កៈ ប្អូនរបស់ពូសព្វថ្ងៃនឹងគាត់រស់នៅណាដែរពូ ប្អូនទី3 នឹងប្អូនទី4អីចឹងហាសពូ?

ខៈ ប្អូនរបស់ខ្ញុំនៅស្រុកនៅក្នុងភូមិនឹង

កៈ ប្អូនទី3នៅណាដែរ?

ខៈ នៅស្រុកភូមិនឹងដែរនឹង

កៈ នៅខេត្តស្វាយរៀងនឹង ចុះទី4វិញ?

ខៈ ទី4នឹងនៅស្រុកដែរនឹង

កៈ ចុះទី5វិញពូនៅស្រុកដែរមែនពូ?

ខ៖ ទី5នឹងទី6នឹងនៅស្រុកទាំងអស់គ្នានឹង

ក៖ ចុះពួកគាត់នៅជិតៗគ្នាមែនពូ?

ខ៖ នឹងហើយនៅជិតៗគ្នានឹង មានប្រពន្ធមានកូននៅណុង

ក៖ ហើយដូចជាពួកគាត់មានគ្រួសារទាំងអស់គ្នានឹងហោសពូ ហើយពួកគាត់ធ្វើអីគេដែរពូនៅណុងហាស?

ខ៖ ធ្វើស្រែអីចឹងទៅ

ក៖ អូធ្វើស្រែទាំងអស់គ្នាតែម្ដងហោសពូ ?

ខ៖ នឹងហើយទាំងអស់គ្នានឹង

ក៖ អត់មានប្រពន្ធគាត់ជួយលក់ដូរអីណាហី គាត់ធ្វើស្រែទាំងអស់តែម្ដងហោសពូ?

ខ៖ ជួនណាប្រពន្ធក៏ជួយលក់ដែរនឹងលក់នៅសាលា

ក៖ ចុះម្ដាយរបស់ពូគាត់មានឈ្មោះអីគេដែរពូ?

ខ៖ ម្ដាយរបស់ខ្ញុំឈ្មោះឡឹក យន្ត

ក៖ គាត់ឈ្មោះឡឹក យន្ត ចុះគាត់អាយុប៉ុន្មានដែរពូ?

ខ៖ គាត់អាយុចិតជាងហើយនឹង

ក៖ អូប៉ុន្តែគាត់នៅរស់តាហីពូ?

ខ៖ ពួកគាត់នៅរស់ទាំងអស់នឹង

ក៖ ចុះគាត់ប្រហែលជាចិតប៉ុន្មានដែរទៅពូ?

ខ៖ គាត់ប្រហែលជា73-74ឆ្នាំដែរហើយនឹង

ក៖ ប៉ុន្តែគាត់កើតនៅឆ្នាំណាពូមានចងចាំទេ?

ខ៖ អូអត់មានចងចាំទេ

ក៖ ចុះគាត់កើតនៅណាពូមានដឹងទេពូ?

ខ៖ មើលពុករបស់ខ្ញុំកើតនៅភូមិស្វាយល្អី ឃុំស្វាយល្អី ស្រុកស្វាយជ្រុំ

ក៖ នៅខេត្តស្វាយរៀងណាពូ នៅស្រុកស្វាយជ្រុំខេត្តស្វាយ នឹងខាងឪពុកណាពូ?

ខ៖ នឹងខាងឪពុកនឹងហើយ

ក៖ ឪពុកឈ្មោះអីគេមិញដែរពូ?

ខ៖ គាត់ឈ្មោះ សុះ ពៅ

ក៖ ចុះម្ដាយហោសពូ?

ខ៖ ម្ដាយឈ្មោះឡឹក យន្ត

ក៖ គាត់អាយុប៉ុន្មានដែរម្ដាយហាសពូ?

ខ៖ ម្ដាយគាត់អាយុ73-74នឹង

ក៖ ចុះឪពុកអាយុប៉ុន្មានដែរពូបងគ្នា1-2ឆ្នាំ?

ខ៖ នឹងហើយថាទៅលើគ្នា3-4ឆ្នាំដែរនឹង

ក៖ ប៉ុន្មានប្រហែលជាប្អូនឆ្នាំណាពូ ចុះម្ដាយរបស់ពូគាត់កើតនៅណាដែរពូ?

ខ៖ កើតនៅភូមិសំរោង

ក៖ នៅភូមិសំរោងហោសពូ?

ខ៖ នឹងហើយស្រុកកំណើតរបស់ខ្ញុំនៅនឹងហាស ប៉ុន្តែឪពុករបស់ខ្ញុំនៅស្វាយល្អី

ក៖ នៅសំរោងនឹងស្រុកអីគេដែរពូ ស្រុកស្វាយជ្រុំដែរមែនពូ?

ខ៖ នឹងហើយនៅស្រុកស្វាយជ្រុំដែរនឹង ប៉ុន្តែឃុំខុសគ្នា

ក៖ ចឹងម្ដាយរបស់ពូគាត់កើតនៅឆ្នាំ1944ហាសពូ?

ខ៖ នឹងហើយប៉ុណ្ណឹងឯងនឹង

កៈ បាទសំរាប់ឪពុករបស់ពូគាត់កើតនៅឆ្នាំ1940ពូ
ប៉ុន្តែចុះម្តាយរបស់ពូគាត់កើតនៅឆ្នាំអីគេពូមានដឹងទេ លក្ខណៈថាឆ្នាំជូត ឆ្លូវ ខាល ថោះពូគាត់ឆ្នាំអីគេដែរ?

ខៈ មើលឪរបស់ខ្ញុំគាត់ឆ្នាំច ម្តាយរបស់ខ្ញុំគាត់ឆ្នាំអីទេនេះ

កៈ ឪពុកឆ្នាំច ប៉ុន្តែពូអត់ចាំក៏មិនអីដែរពូ?

ខៈ ខ្ញុំភ្លេចបាត់ទៅនឹងម៉ែ

កៈ ចុះឪពុករបស់ពូគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរហោសពូ?

ខៈ ឥឡូវនឹងគាត់ធ្វើស្រែមិនបាន បានកូនធ្វើចឹងហាស ចុះបើគាត់ចាស់ៗហើយនឹង គាត់មានស្រែអោយកូនធ្វើទៅ

កៈ ចុះប៉ុន្តែកាលពីមុនគាត់ធ្វើអីគេដែរទៅពូសំរាប់ចិញ្ចឹមជីវិតហាស?

ខៈ កាលពីមុនគាត់ធ្វើស្រែជួញដូរអីនឹងកាលនៅពីមុននឹង

កៈ ចុះគាត់ជាមនុស្សបែបណាដែរពូ គាត់កាចរឺមួយក៏ស្លូតឪពូករបស់ពូហាស?

ខៈ គ្មានកាចអីទេគាត់គួរសមអីចឹងទៅ គាត់បង្រៀនកូនអោយចេះរកស៊ី

កៈ អូបាទពូ ចុះម្តាយគាត់ធ្វើអីគេសំរាប់ចិញ្ចឹមចីវិតដែរពូ?

ខៈ ម្តាយគាត់ធ្វើស្រែដែរនឹង

កៈ គាត់ធ្វើស្រែជាមួយឪពុករបស់ពូហោស?

ខៈ បាទគាត់ដាំស្វាយអីយកទៅលក់ចឹងទៅ

កៈ ចុះម្តាយគាត់ជាមនុស្សបែបណាដែរពូ?

ខៈ ម្តាយរបស់ខ្ញុំមានអីគាត់ស្លូតដែរនឹង

កៈ ចុះឪពុករបស់ពូគាត់មានធ្លាប់ប្រាប់ពិប្រវត្តិគាត់កាលពីនៅក្មេងទៅពូទេ?

ខៈ អូភ្លេចអស់ហើយនឹង

កៈ ចុះម្តាយពូអត់ចាំដែរ?

ខ៖ បាទអត់ចាំទេ

ក៖ ចុះពូមានចងចាំសាច់រឿងអីជាមួយម្ដាយឪពុករបស់ពូកាលពីនៅក្មេងៗទេពូ?

ខ៖ មានអីគាត់ប្រដៅយើងអោយចេះរកស៊ីទៅណា គាត់ណែនាំចឹងទៅណា គ្មានអីទេ

ក៖
ចុះពូមានចងចាំថាកាលពូនៅជាមួយម្ដាយឪពុករបស់ពូដែរពូចាំអត់ភ្លេចហាសដូចជាពូទៅស្រែ រឺក៏ធ្វើអីមួយចឹងហាស?

ខ៖ នឹងហើយ

ក៖ ចុះពូគិតថាមនចងចាំអីគេដែរចាំអត់ភ្លេចទេ រឺមានអនុស្សាវរីយ៍អីជាមួយពួកគាត់អត់ពូ?

ខ៖ គាត់មានតែប្រដៅយើងអោយចេះរកស៊ីចឹង នឹងទៅរែកកណ្ដាប់ រឺដកចឹងទៅណា
ប្រវត្តិគាត់គាត់ប្រដៅអោយយើងអោយមួយល្ងាចចឹងទៅទៅដក
ដល់ពេលព្រឹកយើងទៅស្ទូងទៅ ទាន់ខែរដូវនឹង

ក៖ បាទពូចុះពូមានចងចាំយាយតាខាងឪពុកទេពូ ចាំឈ្មោះពួកគាត់ទេ?

ខ៖ ខ្ញុំមិនសូវដឹងទេពីព្រោះអីគាត់នៅនោះ ខ្ញុំនៅនេះវាឆ្ងាយពីគ្នា

ក៖ ប៉ុន្តែយាយតាខាងឪពុកពូមានស្គាល់ឈ្មោះគាត់ទេ?

ខ៖ ថីមិនស្គាល់ប៉ុន្តែឥឡូវនឹងចង់ភ្លេចហើយនឹង

ក៖ ពួកគាត់មានឈ្មោះអីគេដែរពូ?

ខ៖ គាត់ឈ្មោះយាយសាន

ក៖ ឈ្មោះយាយសាន ចុះតាវិញពូ?

ខ៖ ឈ្មោះតា ស្រីចង់ភ្លេច

ក៖ ឈ្មោះ តាស្រី ចុះយាយតាខាងឪពុកនឹងពូមានដឹងថាគាត់កើតណាឆ្នាំណាដែរទេពូ?

ខ៖ ទេមិនដឹងថាឆ្នាំណាទេគាត់មិនដែរប្រាប់ផងនឹង

ក៖ ប៉ុន្តែយូរណាពូ?

ខ៖ បាទប៉ុន្តែគាត់ស្លាប់យូរហើយនឹង

ក៖ ចុះយាយតាខាងឪពុកនឹងគាត់កើតនៅណាពូមានដឹងទេ?

ខ៖ ខ្ញុំមិនដឹងទេ មិនដឹងថាគាត់កើតនៅណាទេ គាត់មិនប្រាប់ផងនឹង គ្រាន់ថាដឹងខ្លះៗដែរបានន័យថាយើងភ្លេចខ្លះដែរចឹងទៅ

ក៖ បាទពូចុះយាយតាខាងម្តាយពូស្គាល់ឈ្មោះគាត់ទេ មិញយាយតាខាងឪពុកឥឡូវនឹងយាយតាខាងម្តាយពូស្គាល់ឈ្មោះគាត់ទេ?

ខ៖ ចឺមិនស្គាល់ឈ្មោះតាវេង យាយអែ

ក៖ ឈ្មោះតាវេង យាយអែ ចុះគាត់កើតនៅឆ្នាំណាពូមានចងចាំទេ?

ខ៖ អត់ដឹងទេ

ក៖ ប៉ុន្តែគាត់កើតនៅណាពូមានដឹងទេ ដូចជាគាត់កើតនៅភូមិណា ឃុំណាពូមានដឹងទេ?

ខ៖ នឹងហើយគាត់កើតនៅភូមិសំរោង ឃុំគ្រួសនៅនឹងហាស

ក៖ អូនៅជាមួយគ្នាហោសពូ?

ខ៖ បាទហើយ យាយតាខាងឪនឹងនៅឆ្ងាយពីគ្នា នៅខុសឃុំគ្នា

ក៖ អូនៅខេត្តជាមួយគ្នាណាពូ?

ខ៖ នឹងហើយខេត្តជាមួយគ្នា នៅស្រុកជាមួយគ្នានឹង

ក៖ ចុះឪពុកម្តាយរបស់ពូគាត់មានធ្លាប់ប្រាប់ពីប្រវត្តិយាយតាទៅពូទេ?

ខ៖ មានប្រាប់តែឥឡូវនឹងលែងចាំអស់ហើយនឹងមានការភ្លេចច្រើនណាស់ឥលូវនឹង

ក៖ ចុះពូនឹងក្រុមគ្រួសាររបស់ពូយករស់នៅទីក្រុងភ្នំពេញយូរនៅពូ?

ខ៖ ខ្ញុំទើបតែមកដែរនឹង

ក៖ អូទើបតែមក ប៉ុន្តែពូមកនៅប៉ុន្មានឆ្នាំដែរពូ?

ខ៖ មកទើបតែមកបានមួយខែទេនឹងហាស

កៈ អូបានទើបតែបានមួយខែទេ?

ខៈ ដល់ពេលរដូវវស្សាខ្ញុំទៅវិញ

កៈ អូចុះពូមកនៅស្វាយរៀងនឹងបានប៉ុន្មានឆ្នាំដែរហើយពូ?

ខៈ អូនៅស្រុកហោស

កៈ បាទពូនៅអស់ប៉ុន្មានឆ្នាំដែរហើយពូ រឺក៏ពូនៅតាំងពីកើតមករឺយ៉ាងម៉េចដែរពូ?

ខៈ ខ្ញុំនៅតាំងពីកើតនឹង

កៈ តាំងពីកើតចឹងមានន័យថាជាង40ឆ្នាំហើយណាពូ?

ខៈ នឹងហើយ

កៈ ចុះពូមានបងប្អូនរឺមួយក៏សាច់ញ្ញាតិណាដែររស់នៅក្រៅប្រទេសទេពូ ក្រៅពីស្រុកខ្មែរហាសមានទេពូ?

ខៈ ខ្ញុំគ្មានទេ តែបើខាងប្រពន្ធរបស់ខ្ញុំមាន

កៈ គាត់នៅណាដែរពូ?

ខៈ នៅខេត្តស្វាយរៀងដែរនឹង

កៈ ប៉ុន្តែបងប្អូនរបស់ពូនឹងមាននរណាគេទៅរស់នៅ ប្រទេសវៀតណាម ថៃ រឺក៏រស់នៅអាមេរិចអីទេពូ?

ខៈ មានបើខាងសាច់ថ្លៃមាន នឹងខាងប្រពន្ធរបស់ខ្ញុំហាស តែបើខាងខ្ញុំអត់មានទេ

កៈ ចុះខាងសាច់ថ្លៃនឹងគាត់នៅណាដែរពូ?

ខៈ ទៅនៅកូរ៉េ

កៈ អូនៅកូរ៉េហោសពូ គាត់ទៅធ្វើការមែនពូ?

ខៈ ទៅធ្វើការ

កៈ អូបាទពូ ចុះភរិយារបស់ពូគាត់មានឈ្មោះអីគេដែរពូ?

ខ៖ គាត់ឈ្មោះយឹម ណិត

ក៖ អូឈ្មោះ យឹម ណិត ចុះពូមានចងចាំថាពូបានការជាមួយគាត់នៅថ្ងៃខែឆ្នាំណាដែរទេពូ?

ខ៖ ការនឹងវាភ្លេចដែរហើយវាយូរដែរនឹង

ក. ប៉ុន្តែប្រហែលជាប៉ុន្មានឆ្នាំដែរហើយពូមានចងចាំទេ?

ខ៖ មើលអាកូនច្បងឆ្នាំរកា

ក៖ កូនបងរបស់ពូអាយុប៉ុន្មានដែរហើយ?

ខ៖ កូនបងឆ្នាំរកាអាយុម្ភៃជាងរាប់មើល

ក៖ រកា ហើយ រឺកចឹងគាត់ប្រហែលជាអាយុ25ឆ្នាំពូ?

ខ៖ ចឹងទេហោស នឹងខ្ញុំចេះតែភ្លេចៗមិនបានរាប់ដែរនឹង

ក៖ ចឹងពេលដែរពូការហើយពូចាប់ផ្តើមមានកូនតែម្តងណាពូ?

ខ៖ នឹងហើយប្រហែលមួយឆ្នាំនឹង

ក៖ ចឹងពូការនៅឆ្នាំ1993ហាពូ

ខ៖ នឹងហើយប្រហែលជាឆ្នាំ1991-1992នឹងហើយមើលទៅ

ក៖
បាទចឹងដូចជាៗពេលដែរពូរៀបអាពាហ៍ពិពាហ៍នឹងដូចជាឪពុកម្តាយរបស់ពូជាអ្នករៀបចំអោយ រឺក៏ពូរៀបដោយខ្លួនឯងដែរពូ?

ខ៖ កាលណុងបានម្តាយឪពុកដែរ កាលណុងគ្មានស្រលាញ់ខ្លួនឯងទេ តែពុកម៉ែនឹង

ក៖ ប៉ុន្តែមានជាជំនូនទេពូ មានជាបណ្ណាការទេ?

ខ៖ ខ្ញុំនឹងខ្ចិលយក ជំពាក់គេនឹងខ្ចិលរកចេះតែរកតិតុះៗទៅ បាទកុំអោយជំពាក់គេ

ក៖ ចុះពូអាចប្រាប់ពីពេលដំបូងដែរពូបានជួបជាមួយភរិយារបស់ពូបានទេ ដូចជាជួបនៅពេលណា ហើយហេតុអីបានជួបគ្នាចឹងហាស?

ខ៖ កាលណុងបានចាស់ៗៗដែរ

កៈ អូបានចាស់ដែរនពូ?

ខៈ គាត់ចេះតែនាំអ្នកជិតខាងនៅក្នុងភូមិទៅ គេនាំយើងមកមើលអីចឹងទៅណា

កៈ ប៉ុន្តែដូចជាស្រលាញ់ប្រហែលជាប៉ុន្មានខែដែរពូបានចូលស្ដីមឹង?

ខៈ កាលណុងគ្មានទេចាស់ៗសួរហើយទុកបានមួយឆ្នាំដែរបានការ

ក. ចុះហេតុអីបានពូស្រាលាញ់គាត់ដែរពូ
ថាគាត់មានគុណសម្បត្តិអីគេខ្លះដែរចឹងហាសពូ?

ខៈ មានគុណសម្បត្តិមើលទៅមនុស្សស្រីស្លូតបូត បានអាចការជាមួយគ្នាបានក៏យកទៅ

កៈ ចុះពូចេះអានរឺក៏ចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរពូ?

ខៈ អក្សរខ្មែរនឹងសរសេរបានមើលរួចដែរនឹង

កៈ ចុះពូបានរៀនបានថ្នាក់ទីប៉ុន្មានដែរពូ?

ខៈ កាលណុងបានរៀនថ្នាក់ទី7-8ដែរនឹង
ប៉ុន្តែវាមិនចេះអាបារាំងអីគេនឹងដល់ម៉ោងតែមិនចេះយើងខ្ជិលហើយនឹង

កៈ ប៉ុន្តែពូមានចេះភាសាអីក្រៅពីភាសាខ្មែរទេ?

ខៈ គ្មានទេចេះតែខ្មែរទេ

កៈ ចុះកាលណុងពូរៀនបារាំងពូចេះភាសាបារាំងទេ?

ខៈ កាលណុងរៀនបារាំងតែមិនចេះទេ

កៈ ចឹងពូមិនចេះទេណាពូ?

ខៈ ចេះតែអក្សរ តែមិនចេះប្រកបនឹង

កៈ ចុះពូមានចេះវៀតណាម រឺក៏ចេះថៃអីទេ?

ខៈ អត់ទេអត់ចេះទេ

កៈ អត់ទេណាពូចុះកាលណុងពូបានរៀននៅថ្នាក់ទីប៉ុន្មានដែរពូ?

ខ៖ ខ្ញុំរៀនបានថ្នាក់ទី7-8ដែរនឹងកាលណុងនេះ

ក៖ ចុះកាលពូរៀននៅបឋមសិក្សានឹងពូរៀននៅណាដែរពូ?

ខ៖ រៀននៅស្រុក ភូមិនឹង ខេត្ត

ក៖ ចុះសាលាឈ្មោះអីគេដែរពូ សាលាបឋមសិក្សារបស់ពូហាស?

ខ៖ សាលាបឋមកាលណុងពោធំ

ក៖ រៀននៅសាលាពោធំណាពូ?

ខ៖ នឹងហើយនៅពោធំជ្រាំចឹងទៅ

ក៖ ជុះកាលពូរៀនអនុវិទ្យាល័យនឹងពូរៀននៅណាដែរពូ?

ខ៖ អនុវិទ្យាល័យពោធំដែរនឹង

ក៖ នៅពោធំដូចគ្នាណាពូ?
ខ៖ អូកាលខ្ញុំរៀនបានថ្នាក់ទី1ហាសអត់ទាន់មានប្រពន្ធហាស
ខ្ញុំរៀននៅសំរោងសាលាមតេយ្យហាស ដល់ពេលដែរយើងរៀនបានថ្នាក់ទី4
យើងក៏ប្រលងចូលសាលាក្រលះ ពេលដែរយើងប្រលងជាប់ទៅយើងទៅរៀននៅពោធំនឹង

ក៖ បាទពូចុះពូមានមិត្តភក្តិណាដែរស្និទ្ធិស្នាលធំធាត់មកជាមួយគ្នាទេពូ?

ខ៖ បាទថាម៉េចដែរ?

ក៖ មានមិត្តភក្តិណាដែរស្និទ្ធិស្នាលណាដែរធំធាត់មកជាមួយគ្នាអត់ពូ?

ខ៖ ពួកម៉ាក់មានមិនទទេទេ

ក៖ ប៉ុន្តែពូអាចប្រាប់ឈ្មោះពួកគាត់បានខ្លះៗទេ ពូស្គាល់ដែរទេពូ ?

ខ៖ អើរវាពួកម៉ាក់មែនតែមិនសូវជិតស្និទ្ធិនឹងគ្នាទេ ដល់ពេលចឹងដូចជាភ្លេចអស់ហើយ

ក៖ ចុះពូមានចងចាំអនុស្សាវរីយ៍អីដែរពូបានលេងជាមួយមិត្តភក្តិរបស់ពូទេ
កាលពីនៅក្មេងៗពូមានចងចាំទេ?

ខ៖ លេងជាមួយពីណាដែរ?

កៈ លេងជាមួយមិត្តភក្តិរបស់ពូហាស?

ខៈ អូចឹងទេ អើរកាលពីនៅរៀននឹងមានមិត្តភក្តិប្រលែងគ្នាដែរ ប្រលែងគ្នាលេងអីនៅសាលា ពេលដែរយើងចេញលេងអីយើងប្រលែងគ្នាលេងអីចឹងទៅ យើងអោយរំហើយខួរក្បាល ពេលដែរយើងរៀននឹងយើងតក់ក្រម៉លហាសណា អើរយើងចេះតែគិតហាស

កៈ ចុះពូមានចងចាំអនុស្សាវរីយ៍អីដែរពូចងចាំជាមួយមិត្តភក្តិរបស់ពូដែរចាំមិនភ្លេចហាស រឺក៏មានបញ្ហាអីមួយដែរពូចងចាំអត់ភ្លេចទេពូ?

ខៈ មានតា

កៈ ដូចលក្ខណះថាបែកកង់រឺក៏អីគេមួយចឹងហាស?

ខៈ អាណុងវាឥឡូវនឹងគ្នាមេម៉ាយដែរប្រពន្ធស្លាប់ដែរនឹង

កៈ
អូបាទពូចុះពូមាននរណាគេម្នាក់នៅក្នុងក្រុមគ្រួសាររបស់ពូចេះលេងឧបករណ៍ភ្លេងទេពូ?

ខៈ គ្មានទេ ទទេនឹង

កៈ បងប្អូនជីដូនមួយពូក៏មិនចេះដែរ?

ខៈ បាទអត់ចេះទេ

កៈ ចុះផ្ទះរបស់ពូមានលក្ខណះបែបណាដែរពូតាំងពីក្មេងរហូតមកដល់ពេលនេះហាសពូ?

ខៈ ផ្ទះនឹងធ្វើហែៗនឹង ផ្ទះយើងធ្វើហាស

កៈ ចុះកាលពីក្មេងផ្ទះបែបណាដែរទៅពូ?

ខៈ កាលពីក្មេងផ្ទះឈើ ផ្ទះស្លឹកនឹង

កៈ ចុះដល់ពេលឥឡូវនឹង?

ខៈ ឥឡូវនឹងយើងបានប្រកដែកនឹងហាស

កៈ អូបាទពូចុះផ្ទះរបស់ពូនរណាគេជាអ្នកសាងសងដែរពូ?

ខ៖ សាងសងនឹងយើងជួលគេ យើងជួលជាងនឹង

ក៖ អូជួលជាង ប៉ុន្តែពូចេះធ្វើផ្ទះទេពូ?

ខ៖ អើយមិនចេះធ្វើទេ ចេះធ្វើតិចតួចនឹងគ្រាន់ធ្វើរោងគោអីចឹងទៅ

ក៖ ចុះពូមានដឹងថាផ្ទះរបស់ពូធ្វើនឹងគេប្រើឧបករណ៍អីសំរាប់ធ្វើផ្ទះនឹងទេពូ?

ខ៖ មានតែពន្លាក មានតែពូថៅ មានញញួរយើងនឹង រណាជាងអាចឹងទៅ

ក៖ ហើយនឹងឈើណាពូ?

ខ៖ នឹងហើយមានឈើនឹងទៅ

ក៖ ជុះពូគិតថាជំនាញអីដែរពូគិតថាពូចេះតាំងពីក្មេងរហូតមកដល់ពេលនេះហាសពូ ដែរពូគិតថាពូចេះតែម្តងហាសពូ?

ខ៖ គ្មានចេះអីទេចេះតែធ្វើស្រែនឹង

ក៖ ធ្វើស្រែណាពូ ចុះម្តាយឪពុករបស់ពូគាត់ធ្លាប់បង្រៀនពីជំនាញអីទៅកាន់ពូទេ?

ខ៖ ជំនាញជាមិនចេះ យើងចេះខ្លះដែរយើងនៅស្រែនឹង ជំនាញព្រុះស្រូវអីនឹង

ក៖ បាទពូនឹងជំនាញរបស់ពូណាពូ?

ខ៖ នឹងហើយចេះតែចឹង

ក៖ ចុះពូចេះធ្វើកូរស្ករត្នោត រឺវេញល្ហើ ធ្វើផ្តៅ ធ្វើកន្ទេល រឺក៏ចាក់ជាល្អីអីពូចេះទេ?

ខ៖ ខ្ញុំអត់ចេះទេ

ក៖ អូពូអត់ចេះទេណាពូ
ចុះពូគិតថាពេលណាដែរពូគិតថាជាពេលដែរពូសប្បាយនៅក្នុងឆាកជីវិតរបស់ពូដែរហាសពូ?

ខ៖ សប្បាយយើងនឹងសប្បាយនឹងរកស៊ីនឹង ពេលណារកបានទៅសប្បាយហើយ

ក៖ បាទពូចុះពេលដែរពូការរឺក៏កូនរបស់ពូការអីចឹង
រឺធ្វើអោយពូសប្បាយរឺក៏ជួបជុំក្រុមគ្រួសារដែរចឹងហាសពូ?

ខ៖ បាទនឹងហើយសប្បាយនឹងការកូនអីបានរៀបចឹង ហើយពេលកូនរស់នៅជាមួយគ្នាសុខសប្បាយចឹងទៅ យើងក៏សប្បាយដែរទៅ ពេលដែរធ្វើអោយយើងពិបានក៏យើងពិបាកដែរទៅកូននឹងចៅនឹង

ក៖ បាទពូ ចុះពូគិតថាពូធ្វើការងារអីគេខ្លះដែរពូតាំងពីក្មេងរហូតមកដល់ពេលនេះហាសពូ?

ខ៖ គ្មានស្អីទេ កាលយើងនៅស្ទូង ដកនឹង ធ្វើស្រែតែប៉ុណ្ណឹងឯងនឹង

ក៖ នឹងកាលពីក្មេង ចុះឥឡូវនឹងពូ?

ខ៖ ឥឡូវនឹងគ្រាន់តែជំនាញលក់ដូរបន្តិចបន្តួចអីចឹងទៅ ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់

ក៖ ចុះពូគិតថាជីវិតរបស់ពូមានការផ្លាស់ប្តូរអីគេខ្លះដែរទៅពូតាំងពីក្មេងរហូតមកដល់ពេលនេះហាស?

ខ៖ អូផ្លាស់ប្តូរ កាលពីមុនយើងទៅស្ទូង ដក តែឥឡូវនឹងយើងបានរកចឹងទៅ ដល់ពេលដែរគិតទៅវាចេះតែទៀតហើយណា បើយើងរកទៅវាមានចាយ តែបើយើងមិនរកវាអត់ទៅណា

ក៖ បាទពូចុះពូធ្លាប់ទៅធ្វើការនៅវាលស្រែដែរទេពូ?

ខ៖ នឹងហើយធ្វើការ

ក៖ នៅស្រែចំការពូធ្លាប់ធ្វើទេ?

ខ៖ ធ្វើសូម្បីតែឥឡូវនឹងក៏នៅតែធ្វើនឹង ដូចជាព្រុះ ស្រូវស្រែយើងនឹង បើគេមានជំនាញធ្វើអែនឹងក៏ធ្វើអែទៅ បើមិនចេះទេប្រើថ្នាំវាខាតបានមិនធ្វើនឹង

ក៖ បាទពូចុះពូមានធ្លាប់អាជីវកម្មនៅតាមផ្ទះទេពូ ដូចជាលក់ដូរអីចឹងហាស?

ខ៖ គ្មានទេ គ្មានតែម្តងនឹង

ក៖ ចុះពូមានធ្លាប់ចិញ្ចឹមសត្វ ចិញ្ចឹមមាន់ ទា គោអីទេពូ?

ខ៖ មានៗតា

ក៖ មានណាពូ ប៉ុន្តែភាគច្រើននឹងពូចិញ្ចឹមអីគេដែរពូ?

ខ៖ ចិញ្ចឹមគោ

ក៖ ចិញ្ចឹមគោ ចុះចិញ្ចឹមមាន់ ទា អីពូចិញ្ចឹមទេ?

ខ៖ ចិញ្ចឹមមាន់ ទា ជ្រូក ឥឡូវនឹងដាក់ដែរតែវាស្លាប់អស់ទៅ

ក៖ ប៉ុន្តែពូចិញ្ចឹមពីមុនជាលក្ខណៈកសិដ្ឋាន រឺក៏ចិញ្ចឹមជាគ្រួសារដែរពូ?

ខ៖ ចិញ្ចឹមជាលក្ខណៈធម្មតានឹង

ក៖ ចិញ្ចឹមធម្មតាណពូ
ចុះពូមានចងចាំបទចំរៀងណាដែរបូគិតថាតាំងពីក្មេងរហូតមកដល់ពេលនេះពូនៅតែចាំទេពូ?

ខ៖ អត់ទេ

ក៖ អត់ចាំទេណពូ?

ខ៖ យើងចេះតែមើលអក្សរគេទៅ នឹងចេះតែអេអើរៗតាមគេចឹងទៅ

ក៖ ប៉ុន្តែពូចូលចិត្តស្តាប់បទចំរៀងទេ?

ខ៖ មានអីចូលចិត្តដែរតា

ក៖ ជាលក្ខណៈបទបុរាណ រឺបទសម័យដែរពូ?

ខ៖ បទបុរាណដែរនឹងកាលពីមុននឹង

ក៖ អូប៉ុន្តែសម័យនឹងពូចូលចិត្តទេ?

ខ៖ បទសម័យនឹងក៏ចូលចិត្តដែរនឹង

ក៖ អូចឹងមានន័យថាពូចូលចិត្តទាំបុរាណ នឹងបទសម័យដែរ?

ខ៖ នឹងហើយចូលចិត្តទាំងអស់នឹង

ក៖ ចុះពូចូលចិត្តម្ហូបអីគេដែរពូគិតថាពូចូលចិត្តញ៉ាំជាគេដែរហាសពូ?

ខ៖ ចូលចិត្តពិសារសម្លម្ជៀចូលចិត្តជាងគេ

ក៖ អូចុះសម្លការី កកូរ ស្ងោរអីពូចូលចិត្តទេពូ?

ខ៖ ចូលចិត្តធម្មតានឹង

ក៖
ចុះល្បែងប្រជាប្រិយ៍អីដែរពូគិតថាពូចូលចិត្តលេងជាងគេតាំងពីក្មេងរហូតមកដល់ពេលនេះហាសពូ លក្ខណះដូចជាចោលឈូង ទាញព្រាត បោះអង្គុញ លាក់កន្សែងអីចឹងហាស?

ខ៖ នឹងហើយអើរចូលចិត្តកាលពីមុនចុលចិត្តលេងចឹងកាលពីនៅក្មេងនឹង

ក៖ លេងអីគេដែរពូ?

ខ៖ លេងឈូង ទាញព្រាត លាក់កន្សែង ជូនណាមុជទឹកលេងអីចឹងទៅ

ក៖
ចុះពូអាចប្រាប់បានទេគិតថាពេលណាដែរពូលំបាកជាងគេនៅក្នុងឆាកជីវិតរបស់ពូចឹងហាស កាលពីក្មេង រឺក៏ជំនាន់ពលពត រឺក៏ខ្មែរក្រហម រឺពេលពូមានគ្រួសារអីចឹងហាសពូ?

ខ៖ នឹងកាលពីនៅក្មេងវាពិបាកនឹងហាស ពេលកាលពីជំនាន់ពលពតវាជំលាសយើង

ក៖ កាលពីពូកើតមកនៅក្នុងជំនាន់ពលពតនឹងហោសពូ?

ខ៖ នឹងហើយជំនាន់ណុង

ក៖ ប៉ុន្តែពូគេអោយពូធ្វើអីគេដែរទៅពូណ ពូក្មេងៗចឹងគេអោយធ្វើអី?

ខ៖ អូក្មេងៗគេអោយលេងឡឹកឡចឹងទៅកាលណុងនៅចាំ ចាំថាចោលគ្នាលេងចឹងទៅដេញគ្នាលេងអីចឹងទៅ

ក៖ ចុះពូនៅក្មេងចឹងទាហ៊ានគេអត់ធ្វើអីទេណាពូ?

ខ៖ នៅមិនទាន់ធ្វើអីទេ ក្មេងៗគេអោយមើលគោ

ក៖ មើលគោណាពូ?

ខ៖ នឹងហើយមិនសូវមានអីធំដុំទេ

កៈ អូបាទពូ ចុះរបបអាហារកាលពូនៅក្មេងៗគេអោយយ៉ាងម៉េចដែរទៅពូជំនាន់ពលពតហាស?

ខៈ កាលណុងគ្មានទេខ្ញុំមិនទាន់ដល់អាយុ គេអោយមើលគោ វាផ្សំជាមួយនឹងលាមកយើងចឹងហាសគេយកទៅធ្វើជីចឹងទៅ

កៈ ចុះអាយុប៉ុន្មានបានគេអោយទៅមើលគោដែរពូ?

ខៈ កាលណុងអាយុ ខ្ញុំមិនទាន់បានទៅមើលទេ

កៈ ប៉ុន្តែអាយុប៉ុន្មានបានគេអោយទៅមើលដែរពូ ដូចជាអាយុ8-10ឆ្នាំចឹងហាសពូ?

ខៈ អើរនឹងហើយប្រហែលជាប៉ុណ្ណឹង វាប្រហែលជា10ឆ្នាំឡើងគេអោយមើលហើយនឹង

កៈ បាទចុះឪពុកម្តាយរបស់ពូពេលណុងគេអោយនៅណាដែរទៅពូ គេងោយនៅជាមួយគ្នានឹងពូតែម្តងហោសពូ?

ខៈ គេអោយនៅជាមួយគ្នានឹង

កៈ គេអត់ជំលាសទៅណាទេណាពូ?

ខៈ អូកាលណុងឪពុករបស់ខ្ញុំបានឡើងត្នោត

កៈ អូឡើងត្នោតណាពូ?

ខៈ នឹងហើយគេចាត់តាំងអោយឡើងត្នោត

កៈ ចុះបងប្អូនរបស់ពូគេអោយទៅណាទៅចឹង?

ខៈ កាលណុងគ្មានណាមានតែខ្ញុំនឹងបងរបស់ខ្ញុំ2នាក់ មាន3នាក់ប្អូនស្រីមួយដែរ

កៈ ចុះនៅពេលដែរខ្មែរក្រហមនឹងពូនៅប៉ុណ្ណាដែរហើយពូ?

ខៈ អាយុប្រហែលជា5-6ឆ្នាំហើយនឹងហាស

កៈ ប៉ុន្តែពេលណុងគេអោយទៅធ្វើអីគេទៅ គេមិនអោយធ្វើអីណាហីពូ?

ខ៖ គ្មានធ្វើអីប្រលែងគ្នាលេងចឹងទៅ យើងលេងឡឹកឡ កាលពីនៅក្មេងៗហាសកាលណុងក្មេងៗជុំគ្នាគេប្រមូលមកជុំគ្នាចឹងទៅ ទាំងស្រុកគេស្រុកឯងចឹងទៅ

ក៖ ចុះពេលដែរពូមានក្រុមគ្រួសារនឹងពូគិតថាមានការជួបទុកលំបាកអីគេដែរខ្លះទៅពូ?

ខ៖ ពិបាកនឹងវាមានការពិបាកនឹង យើងមិងបាច់និយាយទេពិបាកនឹងវាពិបាកហើយណាមួយយើងគ្មានដែរថាវាគិតទៅវាពិបាកដែរទៅ

ក៖ ចុះពូឆ្លងកាត់ការលំបាកយ៉ាងម៉េចដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាសពូគិតថាជំនះវាដោយរបៀបណាដែរពូ?

ខ៖ ឆ្លងកាតវាថាអានឹងវាពិបាកនឹង អារម្មណ៍ខ្លួនយើងទប់កុំអោយអារម្មណ៍ពិបាកនឹងយើងអោយវាច្បាស់ទៅណាយើងដើរលេងចឹងទៅវាភ្លេចហើយ

ក៖ ចុះពេលដែរពូនៅពីក្មេងហាសពូមានធ្លាប់មានក្តីស្រម៉ៃថាចង់ធ្វើអីទេដូចថាចង់ធ្វើជាគ្រូពេទ្យ រឺគ្រូបង្រៀនអីចឹងហាស?

ខ៖ ចង់ធ្វើគ្រូអីចឹងហាស

ក៖ ចង់ធ្វើគ្រូនឹងកាលពីពូនៅរៀនណាពូ?

ខ៖ នឹងហើយការនៅរៀននឹង

ក៖ ហេតុអីបានជាពូស្រលាញ់គ្រូដែរពូ ហេតុអីទៅ?

ខ៖ ស្រលាញ់គ្រូដោយសារតែយើងបានបង្រៀនសិស្ស អោយចេះតៗគ្នាទៅទៀតហាស

ក៖ អូអោយគាត់សាងអនាគត់បានល្អនឹងអោយគាត់ជួយប្រទេសជាត់ដែរណាពូ?

ខ៖ បាទចឹងហើយ

ក៖ ចុះបើចង់អោយពូផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗតើពូចង់ផ្តែផ្តាំអីគេខ្លះដែរទៅពូ?

ខ៖ ផ្ដែផ្ដាំថាអោយក្មេងខំរៀន នឹងខំសូត្រចឹងទៅ
ព្រោះស្រុកយើងឥឡូវនឹងវាសំបូរសប្បាយហើយនឹងឯងនឹង
អោយតែចេះមិនខ្លះទេការងារនឹង

ក៖ បាទពូចុះមានអីចង់ផ្ដែផ្ដាំទៀតទេពូ?

ខ៖ ផ្ដាំថាអោយតែសុខសប្បាយរហូតនឹង

ក៖ ចឹងអត់មានអីទៀតទេណាពូ?

ខ៖ បាទៗអត់មានទេ

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណពូ
ដែរបានចំណាយពេលវេលាដែរបានពិភាក្សាជាមួយខ្ញុំដែរទាក់ទងទៅនឹងប្រវត្តិរបស់ពូដែរ
ហើយដូចជាការសំភាសន៍ពូនឹងខ្ញុំនិងយកទៅរក្សាទុកនៅក្នុងសាលា
ហើយជាចុងក្រោយខ្ញុំងរគុណពូ
ហើយខ្ញុំជូនពរពូមានសុខភាពល្អនឹងរកស៊ីមានបានដែរចឹងហាសពូ
នឹងមានសុភម្គលនៅក្នុងក្រុមគ្រួសារដែរចឹងហាសពូ

ខ៖ បាទអរគុណដែរ

ក៖ បាទអរគុណច្រើនពូ៕៕៕